ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

** **

សាលាដំបូងខេត្តសៀមរាប

<u>សាលក្រមលេខ:</u> ៣៨ ខ.១/៨៥៨

ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

<u>សំណុំរឿងព្រហ្មទណ្ឌលេខ:</u> ១៥៤០

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

<u>សំណុំរឿងជម្រះលេខ:</u> ២៦៨

ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

# <u>តាមនាមប្រជាពលរដ្ឋខ្មែរ</u>

## <u>សាលាដំបូងខេត្តសៀមរាប</u>

ដែលបានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាប

-បើកសវនាការថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ៨:៣០នាទីព្រឹក

-ប្រកាសសាលក្រមនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ៩:០០នាទីព្រឹក។

ដោយមានសមាសភាពដូចខាងក្រោម៖

**<u>ចៅក្រមជំនុំជម្រះ</u>**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តសៀមរាប

**<u>តំណាងអយ្យការ</u>**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

<u>ដើម្បីជំនុំជម្រះ</u> រឿងក្ដីព្រហ្មទណ្ឌលេខៈ១៥៤០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] វត្ថា ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ បច្ចុប្បន្នជាប់ឃុំក្នុងពន្ធនាគារខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ប្រពន្ធឈ្មោះ [redacted] ឌូវ៉ា មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] សុខុម (ស្លាប់) ម្ដាយឈ្មោះ [redacted] សុខេង (រស់) កំពុងជាប់ពន្ធនាគារខេត្តសៀមរាប។ (ក្នុងឃុំ)

ជាប់ចោទពីបទ "ប្រគល់ដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៥៧១ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] វត្ថា។

២-ឈ្មោះ [redacted] ប៊ុនហ៊ាង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើតភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប បច្ចុប្បន្នជាប់ឃុំក្នុងពន្ធនាគារខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៧ នៅលីវ ឪពុកឈ្មោះ [redacted] គីង (រស់) ម្ដាយឈ្មោះ [redacted] មុយអៀង (រស់) កំពុងជាប់ពន្ធនាគារខេត្តសៀមរាប។ (ក្នុងឃុំ)

ជាប់ចោទពីបទ "ទទួលដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៥៧២ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

## រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១១និង៣០នាទី មន្ត្រីពន្ធនាគារខេត្តសៀមរាប បានធ្វើការឆែកឆេរដកហូតបានទូរស័ព្ទចំនួន ០១គ្រឿង ម៉ាកនូគារ ១០៣៤ ពណ៌ទឹកសមុទ្រ ជារបស់ជនជាប់ឃុំឈ្មោះ [redacted] ប៊ុនហ៊ាង ឃុំខ្លួននៅអាគារC ប្រឡោះកណ្តាល យោងតាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ប៊ុនហ៊ាង បាននិយាយថាទូរស័ព្ទខាងលើនេះគឺខ្លួនបានមកពីឈ្មោះ [redacted] វត្ថា ដែលឃុំខ្លួននៅអាគារC ប្រឡោះកណ្តាលបានប្រគល់មកឱ្យខ្លួន។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ២២៧ អ.យ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញដីកាដំណោះស្រាយលេខ: ១៤៧៩ ពស.ព្រស ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៧២ ពស.ព្រជ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## ពេលសវនាការ

## ក្រោយពីបាន

-ស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] វត្ថា និងឈ្មោះ [redacted] ប៊ុនហ៊ាង

-ពិនិត្យលើរបាយការណ៍ស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

## សំអាងហេតុ

១/លទ្ធផលនៃកិច្ចពិភាក្សាដេញដោលពិនិត្យភស្តុតាងនាពេលសវនាការ និងយោងតាមរបាយការណ៍ស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌បង្ហាញឱ្យឃើញថាពិតជាមានអំពើ "**ប្រគល់ដោយខុសច្បាប់ និងទទួលដោយខុសច្បាប់**" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ប្រាកដមែន។

២/<u>ភស្តុតាងដាក់បន្ទុកមាន:</u>

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វត្ថា បានឆ្លើយថា ខ្លួនទទួលស្គាល់ថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយកាលពីថ្ងៃចន្ទ ទី២១ ខែធ្នូ ឆ្នាំ២០២០ ខាងមន្ត្រីការិយាល័យប្រតិបត្តិ គាត់បានមកឆែកឆេរអាគារC បន្ទប់ប្រឡោះកណ្តាល ហើយឆែកឆេរមិនបានអ្វីនោះទេ។ នៅពេលដែលមន្ត្រីខាងការិយាល័យប្រតិបត្តិឆែកឆេរមិនបានអ្វីទេ ក៏ត្រឡប់ទៅវិញ។ លុះដល់ម៉ោងបើកបាយដាក់តាមបន្ទប់ ខ្លួនបានសុំសោរពីមន្ត្រីពន្ធនាគារប្រចាំអាគារនោះដើម្បីបើកសោរដាក់បាយដាក់សម្លរ ហើយសោរបន្ទប់នោះបើកចូលទៅតាមផ្លូវក្រោយ នៅពេលដែលខ្លួនដើរទៅបើកសោរបន្ទប់ខាងក្រោយអាគារក៏ឃើញទូរស័ព្ទមួយគ្រឿងម៉ាក ណូគាចុចពិលបែកអេក្រង់ ខ្លួនក៏រើសយកមកទុកគ្រាន់ទាក់ទងទៅអ្នកផ្ទះ លុះដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ពេលថ្ងៃឈ្មោះ ផេង ប៊ុនហ៊ាង ដែលជាជំនួយការមន្ត្រីពន្ធនាគារដូចខ្លួនរបស់ដែរ គាត់បានសុំទូរស័ព្ទខ្លួនដើម្បីទាក់ទងទៅអ្នកផ្ទះដើម្បីទិញថ្នាំរមាស់ និងម្ហូបញ៉ាំ ពេលនោះមន្ត្រីខាងការិយាល័យ

Scanned with CamScanner

ប្រតិបត្តិបានចូលមកដកយកទូរស័ព្ទពីឈ្មោះ [redacted] ប៊ុនហ៊ាង តែម្តង។ ដោយសារឈ្មោះ [redacted] ប៊ុនហ៊ាង ដេកនៅក្នុងបន្ទប់ជាមួយខ្លួន ហើយគាត់ឃើញខ្លួនតេទូរស័ព្ទទៅអ្នកផ្ទះ។ ខ្លួនមិនដឹងទេថា ការយកទូរស័ព្ទមកនិយាយក្នុងពន្ធនាគារមានបទល្មើស ខ្លួនគិតស្មានតែនៅពេលខាងមន្ត្រីពន្ធនាគារចាប់បានគ្រាន់ជាប់ពិន័យក្នុងពន្ធនាគារ មិនដឹងថាមានទោស បើខ្លួនដឹងថាមានទោសដូច្នេះ ខ្លួនមិនបានប្រព្រឹត្តទេ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនហ៊ាង បានឆ្លើយថា ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានសុំទូរស័ព្ទពីឈ្មោះ [redacted] វត្ថា ដើម្បីតេទៅរកបងស្រីបង្កើតខ្លួន ដើម្បីឱ្យគាត់ទិញថ្នាំព្យាបាលរមាស់ឱ្យខ្លួនមែន។ ខ្លួនសុំទូរស័ព្ទឈ្មោះ [redacted] វត្ថា ជាលើកទី១ តែប៉ុណ្ណោះ។ ហើយឈ្មោះ [redacted]វត្ថា មិនបានសុំលុយថ្លៃនិយាយទូរស័ព្ទពីខ្លួននោះទេ ប៉ុន្តែខ្លួនតែងតែចែកដូចជា នំ ទឹកក្រូច ដល់គាត់នៅពេលដែលគ្រួសារខ្លួនមកមើល និងផ្ញើវ៉ាន់ឱ្យខ្លួន។ ខ្លួនមិនដឹងថាឈ្មោះ [redacted]វត្ថា មានទូរស័ព្ទប្រើនោះទេ ប៉ុន្តែនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១១ពេលថ្ងៃ ខ្លួនបានដើរទៅបន្ទប់ទឹកក៏ឃើញឈ្មោះ[redacted] វត្ថា មានកាន់ទូរស័ព្ទនៅនឹងដៃ ពេលនោះខ្លួនសុំគាត់តេទៅអ្នកផ្ទះតែម្តង។ ខ្លួនមិនដឹងថាឈ្មោះ [redacted] វត្ថា បានទូរស័ព្ទមកពីណានោះទេ និងមិនដឹងថាការសុំទូរស័ព្ទពីអ្នកដទៃយកមកនិយាយក្នុងពន្ធនាគារមានបទល្មើសដែរ។

៣/មានភស្តុតាងគ្រប់គ្រាន់កំណត់ពិរុទ្ធភាព: លើជនជាប់ចោទឈ្មោះ [redacted] វត្ថា ភេទប្រុស ពីបទ "ប្រគល់ដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៧១ នៃក្រមព្រហ្មទណ្ឌ។ ចំណែកឈ្មោះ [redacted] ប៊ុនហ៊ាង ភេទប្រុស ពីបទ "ទទួលដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៧២ នៃក្រមព្រហ្មទណ្ឌ។

៤/អំពីការប្រកាសទោស: គប្បីតុលាការប្រកាសទោសដាក់ពន្ធនាគារដល់ជនជាប់ចោទក្នុងកម្រិតអប្បបរមានៃទោស។

៥/វត្ថុតាងរួមមាន: ទូរស័ព្ទដៃ NOKIA Model: TA-1034 ពណ៌ទឹកសមុទ្រ (បែកអេក្រង់មុខ) ចំនួន ០១គ្រឿង គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

៦/សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ: លោក [redacted] ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] វត្ថា បានធ្វើការស្នើសុំឱ្យតុលាការមេត្តាបន្ធូបន្ថយទោសដល់ជនជាប់ចោទដោយក្តីអនុគ្រោះ ហេតុថា កូនក្តីរបស់ខ្ញុំបាទពុំបានដឹងថា ការប្រើប្រាស់ទូរស័ព្ទក្នុងពន្ធនាគារជាបទល្មើសនោះទេ។

៧/សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ: បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ២២៧ អ.យ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ទុកនៅទាំងស្រុង។

យល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹមត្រូវ។

## ហេតុដូច្នេះទើបសម្រេច

១/ផ្តន្ទាទោស:

ក-ឈ្មោះ [redacted]ត្ថា ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើត ភូមិ[redacted] ខេត្តកំពង់ធំ បច្ចុប្បន្នជាប់ឃុំក្នុងពន្ធនាគារខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ប្រពន្ធឈ្មោះ [redacted] នូរ៉ា មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] សុខុម (ស្លាប់) ម្តាយឈ្មោះ[redacted]សុខេង (រស់) កំពុងជាប់ពន្ធនាគារខេត្តសៀមរាប។ (ក្នុងឃុំ)

**ដាក់ពន្ធនាគារ កំណត់ ០៤ (បួន) ខែ។**

ជាប់ចោទពីបទ "ប្រគល់ដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៧១ នៃក្រមព្រហ្មទណ្ឌ។

ខ-ឈ្មោះ [redacted]ប៊ុនហ៊ាង ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើតភូ[redacted] ខេត្តសៀមរាប បច្ចុប្បន្នជាប់ឃុំក្នុងពន្ធនាគារខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី០៧ នៅលីវ ឪពុកឈ្មោះ [redacted] គីង (រស់) ម្តាយឈ្មោះ[redacted]មុយអៀង (រស់) កំពុងជាប់ពន្ធនាគារខេត្តសៀមរាប។ (ក្នុងឃុំ)

**ដាក់ពន្ធនាគារ កំណត់ ០៤ (បួន) ខែ។**

ជាប់ចោទពីបទ "ទទួលដោយខុសច្បាប់" ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥៧២ នៃក្រមព្រហ្មទណ្ឌ។

២/វត្ថុតាងរួមមាន: ទូរស័ព្ទដៃ NOKIA Model: TA-1034 ពណ៌ទឹកសមុទ្រ (បែកអេក្រង់មុខ) ចំនួន ០១គ្រឿង ត្រូវសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

៣/សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទទាំងពីរ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា

[redacted] | [redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

សៀមរាប, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

បានឃើញ

**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី**

[redacted] | [redacted]

Scanned with CamScanner